ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

# សារជូនពរ

## ផ្ញើជូន

## នាយទាហាន នាយទាហានរង និងពលទាហាន នៃកងយោធពលខេមរភូមិន្ទ

## ក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំសកល២០២៤

***មេបញ្ជាការ មេបញ្ជាការរង នាយទាហាន នាយទាហានរង និងពលទាហាន គ្រប់ស្ថាប័ន កងឯកភាព នៃកងយោធពលខេមរភូមិន្ទទាំងអស់ ជាទីស្នេហា !***

ក្នុងឱកាសដ៏វិសេសវិសាល ពោរពេញដោយសេចក្តីសោមនស្សរីករាយ ក្នុងទិវាចូលឆ្នាំថ្មី ឆ្នាំសកល២០២៤ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ នៃកងយោធពលខេមរភូមិន្ទ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ សូមផ្ញើជូននូវការសាកសួរសុខទុក្ខដោយក្តីនឹករលឹក និងជាទីស្រឡាញ់រាប់អានយ៉ាងជ្រាលជ្រៅបំផុត ចំពោះមេបញ្ជាការ មេបញ្ជាការរង នាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ ក្នុងកងយោធពលខេមរភូមិន្ទ ដែលកំពុងបំពេញភារកិច្ចនៅតាមស្ថាប័ន កងឯកភាពនានា នាយទាហានដែលកំពុងសម្រាកព្យាបាលជំងឺ ក៏ដូចជាសិក្ខាកាមកំពុងសិក្សាជំនាញផ្សេងៗទាំងនៅក្នុងប្រទេស និងក្រៅប្រទេស ព្រមទាំងកងកម្លាំងបំពេញបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ។

ខ្ញុំសូមយកឱកាសនេះ ផ្តាំផ្ញើសាកសួរសុខទុក្ខជាមួយនឹងសេចក្តីនឹករឭក និងសូមជូនសព្ទសាធុការពរជ័យ សិរីមង្គល វិបុលសុខ មហាប្រសើរ ជូននាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ ក្នុងកងយោធពលខេមរភូមិន្ទ ឱ្យទទួលបាននូវសុខភាពល្អ កម្លាំងពលំមាំមួនចៀសផុតអំពីជំងឺផ្សេងៗ និងសម្រេចបានជោគជ័យគ្រប់ភារកិច្ច ទទួលបានកិត្តិយសកេរ្តិ៍ឈ្មោះជូនជាតិមាតុភូមិនៃយើង។

នាឱកាសនេះ ខ្ញុំសូមសម្តែងនូវមោទនភាព និងកោតសរសើរយ៉ាងស្មោះចំពោះជោគជ័យដ៏ត្រចះត្រចង់នូវសមិទ្ធផលដ៏ធំធេងក្នុងឆ្នាំកន្លងមក ដែលកងយោធពលខេមរភូមិន្ទយើងសម្រេចបាន គឺកើតចេញពីការលះបង់ និងការខិតខំពុះពារជម្នះគ្រប់ឧបសគ្គនិងការលំបាក ធ្វើពលិកម្មគ្រប់បែបយ៉ាងដើម្បីការពារជាតិមាតុភូមិ ការពារសន្តិសុខជាតិ ស្ថិរភាពនយោបាយ ឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដីបានយ៉ាងគង់វង្សគ្រប់កាលៈទេសៈ ពង្រឹងខឿនការពារជាតិ និងសុខក្សេមក្សាន្តរបស់ប្រជាជន។ ខ្ញុំសូមកោតសរសើរនិងវាយតម្លៃខ្ពស់ ចំពោះកងយោធពលខេមរភូមិន្ទ ដែលបានចូលរួមចំណែកយ៉ាងសកម្មក្នុងប្រតិបត្តិការសង្គ្រោះគ្រោះមហន្តរាយ និងជំនួយមនុស្សធម៌ផ្សេងៗ លើសពីនេះកងទ័ពត្រូវបានចាត់ទុកជាកម្លាំងនាំមុខក្នុងយុទ្ធនាការផ្សេងៗទូទាំងប្រទេសដែលជាមោទនភាពបំផុត ជាពិសេសក្នុងការសង្គ្រោះអាយុជីវិតរបស់ប្រជាពលរដ្ឋពីការឆ្លងរីករាលដាលនៃជំងឺដ៏កាចសាហាវនានា។ ម្យ៉ាងទៀត កងយោធពលខេមរភូមិន្ទយើងបានចូលរួមអនុវត្តប្រកបដោយជោគជ័យនូវភារកិច្ចអន្តរជាតិលើវិស័យមនុស្សធម៌សកលលោក បំពេញបេសកកម្មជាកងកម្លាំងរក្សាសន្តិភាពក្រោមឆត្ររបស់អង្គការសហប្រជាជាតិ ដើម្បីបុព្វហេតុសន្តិភាព និងកិច្ចសហប្រតិបត្តិការអន្តរជាតិល្អ ដែលជាមោទនភាព និងជាកិត្តិយសដ៏ខ្ពង់ខ្ពស់ឧត្តុង្គឧត្តមយ៉ាងក្រៃលែងរបស់កងយោធពលខេមរភូមិន្ទ ក៏ដូចជាប្រជាជាតិកម្ពុជាយើងទាំងមូលធ្វើឱ្យកិត្យានុភាពរបស់ព្រះរាជាណាចក្រកម្ពុជាកាន់តែល្បីរន្ទឺនៅលើឆាកអន្តរជាតិ។

វិថីហ្សកនីមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទលេខ០២៣ ៨៨៣ ២៧៨: generalsec@mod.gov.kh

***- មេបញ្ជាការ មេបញ្ជាការរង នាយទាហាន នាយទាហានរង និងពលទាហាន នៃកងយោធពលខេមរភូមិន្ទ ជាទីស្នេហា !***

ជាថ្មីម្តងទៀត ក្នុងទិវាចូលឆ្នាំថ្មីឆ្នាំសកលនេះ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ និងក្នុងនាមខ្ញុំផ្ទាល់ សូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក មានទេវតារក្សាទឹកដីនៃព្រះរាជាណាចក្រកម្ពុជា សូមជួយប្រោះព្រំសព្វសាធុការពរជ័យ សិរីមង្គល ជូនចំពោះមេបញ្ជាការ មេបញ្ជាការរង គ្រប់ស្ថាប័ន កងឯកភាព និងនាយទាហាន នាយទាហានរង និងពលទាហានទាំងអស់ ក្នុងកងយោធពលខេមរភូមិន្ទ ព្រមទាំងសិក្ខាកាមទាំងអស់ដែលកំពុងបំពេញការសិក្សាជំនាញផ្សេងៗ នៅតាមបណ្តាប្រទេសជាមិត្ត រួមទាំងកងកម្លាំងបំពេញបេសកកម្មរក្សាសន្តិភាពក្រោមកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់អង្គការសហប្រជាជាតិ នឹងក្រុមគ្រួសារទទួលបាននូវសុខភាពល្អបរិបូរណ៍ កម្លាំងកាយមាំមួនខ្លាំងក្លា ប្រាជ្ញាឈ្លាសវៃ អាយុយឺនយូរ និងសម្រេចបានជោគជ័យគ្រប់ភារកិច្ច ជូនជាតិមាតុភូមិ។

សូមផ្ញើជូននូវការសួរសុខទុក្ខ និងជូនពរដល់យោធិន ដែលកំពុងសម្រាកព្យាបាលនៅតាមមន្ទីរពេទ្យនានា សូមឱ្យឆាប់ជាសះស្បើយពីជំងឺ មានសុខភាពល្អបរិបូរណ៍ កម្លាំងមាំមួន និងប្រកបដោយសេចក្តីសុខគ្រប់ពេលវេលា និងសូមជូនពរដល់អតីតយុទ្ធជន ព្រមទាំងក្រុមគ្រួសារដែលកំពុងរស់នៅក្នុងសង្គមស៊ីវិល សូមមានជីវភាពរស់នៅបានធូរធា និងប្រកបដោយសុភមង្គលរុងរឿងជានិច្ច។

សូមទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** ជានិច្ចនិរន្តរ៍តរៀងទៅ។

ថ្ងៃសុក្រ ២រោច ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ សីហា**